# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១៧៧០ ប្រក. កសក

# ប្រកាស

## ស្ដីពី

## ការចុះបញ្ជីសហគមន៍នេសាទចំនួន០៤ នៅខេត្តកោះកុងនិងខេត្តតាកែវ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្មនិងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ១២៣ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការកំណត់ប្រភេទផលផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់
- បានឃើញប្រកាសលេខ ៦៨១ ប្រក.កសក.ប ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យនិងមន្ទីរពិសោធន៍ចំណុះនាយកដ្ឋាន និងវិទ្យាស្ថានក្រោមឱវាទរដ្ឋបាលជលផល
- បានឃើញប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

# សម្រេច

**ប្រការ ១.-**

ត្រូវបានចុះបញ្ជីជាផ្លូវការនិងទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវសហគមន៍នេសាទចំនួន០៤រួមមាន៖ ខេត្តកោះកុងចំនួន០៣ សហគមន៍និងខេត្តតាកែវចំនួន០១ សហគមន៍ ដែលមានឈ្មោះសហគមន៍នេសាទ ចំនួនសមាជិក ចំនួនគណៈកម្មការ ទំហំកន្លែងនេសាទសហគមន៍ ឈ្មោះឃុំ ស្រុក ខេត្ត និងនិយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ដូចមាននៅក្នុងតារាងនិងផែនទីកន្លែងនេសាទសហគមន៍នីមួយៗជាឧបសម្ព័ន្ធ ភ្ជាប់ប្រកាសនេះ ។

**ប្រការ ២.-**

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗ ដែលបានកំណត់ក្នុងផែនទី ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវបានទទួលស្គាល់ដោយនាយខណ្ឌរដ្ឋបាលជលផល អាជ្ញាធរដែនដី ប្រធានរដ្ឋបាលជលផល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ៣.-**

ទំហំកន្លែងនេសាទសហគមន៍ និយាមកាជាចំណុចគោលនៃព្រំប្រទល់កន្លែងនេសាទសហគមន៍ ចំនួនភូមិ និងទីតាំងភូមិសាស្ត្ររបស់សហគមន៍ ដូចមានចែងក្នុងប្រការ ១ អាចកែប្រែបានតាមការចាំបាច់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ៤.-**

ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥.-**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្មខេត្តពាក់ព័ន្ធ និងប្រធានសហគមន៍នេសាទត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២

**រដ្ឋមន្ត្រី**

**ចាន់.សារុន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- សាលាខេត្តពាក់ព័ន្ធ
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធ:** ភ្ជាប់ប្រកាសលេខ......១៧០ (ប្រក.កសក......ចុះថ្ងៃទី០៤........ខែឧសភា..........ឆ្នាំ២០១២

## សហគមន៍នេសាទក្នុងខេត្តកោះកុងនិងខេត្តតាកែវ

| ល.រ | ឈ្មោះសហគមន៍នេសាទ | ចំនួនសមាជិក | ចំនួនសមាជិកគណៈកម្មការសហគមន៍ | ទំហំផ្ទៃសហគមន៍ (ហិកតា) | ភូមិ | ឃុំ/សង្កាត់ | ស្រុក/ក្រុង | Projection :UTM, Everest 1830, Datum : Indian 1960, Zone : 48 N (X,Y) | (X,Y) |
|---|---|---|---|---|---|---|---|---|---|
| **១-ខេត្តកោះកុង** | | | | | | | | | |
| ១ | ឃុំភ្ញីមាស | ១៧៩ | ៧ | ៤.៨០៨ | ភ្ញីមាស តានី កៀនក្រឡាញ់ | ភ្ញីមាស | គិរីសាគរ | A. (292278, 1225766)<br>B. (293312, 1232813)<br>C. (291811, 1232905) | D. (289896, 1221526)<br>E. (291298, 1219771)<br>F. (293189, 1219186) |
| ២ | ឃុំកណ្តាល | ២៤២ | ៧ | ២.៥៦០ | ធ្នង់ | កណ្តាល | បុទុមសាគរ | A. (337275, 1234321)<br>B. (342340, 1234094) | C. (337654, 1234701)<br>D. (339551, 1224970) |
| ៣ | ឃុំជ្រោយប្រស់ | ១៨០ | ៩ | ១១.០៨៥ | ថ្មី | ជ្រោយប្រស់ | កោះកុង | A. (284911, 1243986)<br>B. (285169, 1245040)<br>C. (285921, 1246408) | D. (291899, 1259152)<br>E. (292834, 1255007)<br>F. (294126, 1257143) |
| **២-ខេត្តតាកែវ** | | | | | | | | | |
| ១ | បាស្រែ | ៦១៤ | ៧ | ១.៤១១ | បាស្រែ ពូនគក តាអី ព្រៃបាសឹង ស្វាយខាងជើង និងស្វាយខាងត្បូង | បាស្រែ | អង្គរបុរី | A. (497000, 1223000)<br>B. (503000, 1223000)<br>C. (503014, 1220004) | D. (499640, 1219974)<br>E. (500385, 1221404)<br>F. (500280, 1221530) |

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០១២

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ**

ចាន់ សារុន

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

ណៅ ធួក